# លក្ខន្តិកៈកាតឥណទាន
# ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

មានសុពលភាពចាប់ពី ខែ សីហា ឆ្នាំ២០១៩

J Trust Royal Bank

មាតិកា ទំព័រ


ការទទួលស្គាល់ទូទៅ 1
1. ការពន្យល់អំពីលក្ខខណ្ឌ 1
ការផ្តល់កាត 3
2. កាតព្វកិច្ចនៃការទូទាត់របស់អ្នកប្រើប្រាស់កាត 3
ការប្រើប្រាស់កាត 4
3. ការហាមឃាត់ក្នុងការប្រើប្រាស់កាត 4
4. ប្រតិបត្តិការលើការទិញទំនិញ 4
5. ប្រតិបត្តិការសាច់ប្រាក់ 5
6. ការប្រើប្រាស់លេខកូដសម្ងាត់ផ្ទាល់ខ្លួន 5
7. របាយការណ៍ 5
8. ភាពជាម្ចាស់កម្មសិទ្ធិនៃកាត 6
9. ការណែនាំអ្នកប្រើប្រាស់កាត 7
10. ការកែប្រែព័ត៌មាន 7
11. ការលើកលែង 8
12. កាតត្រូវបានបាត់បង់ ឬចោរលួច 8
13. ប្រតិបត្តិការបង្វិលប្រាក់សងវិញ 9
14. រយៈពេលកំណត់នៃប្រតិបត្តិការបង្វិលប្រាក់សងវិញ 9
15. ការបញ្ឈប់ដោយអ្នកប្រើប្រាស់កាត 9
16. ទំនាក់ទំនងតាមទូរស័ព្ទ 9
17. ការជូនដំណឹងពីអ្នកផ្តល់កាត 10
ចំនួនកម្រិតឥណទាន 10
18. ការលើសចំនួនកំណត់ 10
19. ការបង្កើន/ បន្ថយកម្រិតឥណទាន 10
20. វិធីសាស្ត្រទូទាត់ 10
21. ចំនួនត្រូវទូទាត់ 11
22. ការអនុវត្តលើការទូទាត់ 11

| | | |
|---|---|---|
| 23. | ប្រតិបត្តិការរូបិយប័ណ្ណបរទេស | 12 |
| 24. | អត្រាការប្រាក់ | 12 |
| 25. | រយៈពេលមិនគិតការប្រាក់ចំពោះប្រតិបត្តិការលក់ | 12 |
| 26. | ការគណនាអត្រាការប្រាក់ | 12 |
| 27. | ការមិនគោរពតាមកិច្ចសន្យា | 13 |
| | ថ្លៃសេវាកម្ម | 14 |
| 28. | ថ្លៃសេវាកម្ម | 14 |
| | បទបញ្ញត្តិផ្សេងទៀត | 15 |
| 29. | ការព្រមព្រៀងចំពោះព័ត៌មានផ្ទាល់ខ្លួន | 15 |
| 30. | កាតបន្ទាប់បន្សំ | 15 |
| 31. | ការកែប្រែបទបញ្ញត្តិ និងលក្ខខណ្ឌ | 16 |
| 32. | ការទទួលខុសត្រូវរបស់អ្នកផ្តល់កាតចំពោះការខូចខាត | 16 |
| 33. | ការលើកលែងចំពោះការបំពានកិច្ចសន្យា | 16 |
| 34. | ភាពដែលអាចចាត់ទុកដោយឡែក | 16 |
| 35. | ច្បាប់គ្រប់គ្រង | 17 |
| 36. | ជម្លោះ | 17 |
| 37. | កាតដែលមានការធានា | 17 |
| 38. | ការប្រឆាំងការលាងលុយកខ្វក់ ភេរវកម្មហិរញ្ញវត្ថុនិង ការត្រួតពិនិត្យទណ្ឌកម្មហិរញ្ញវត្ថុ | 17 |
| 39. | ការផ្ទេរសិទ្ធិរបស់អ្នកផ្តល់កាត | 18 |
| 40. | ការប្រមូលព័ត៌មាន | 18 |
| 41. | ពន្ធអាករ | 18 |

# បទបញ្ញត្តិ និងលក្ខខណ្ឌចំពោះកាតឥណទាន ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

លក្ខខណ្ឌកាតឥណទានធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ស្តីពីការផ្តល់ជូន និងការប្រើប្រាស់កាតឥណទានធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ យោងតាមការយល់ព្រមពីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានប្រសិទ្ធិភាពចាប់ពីខែ សីហា ឆ្នាំ 2019 ។

## ការទទួលស្គាល់ទូទៅ

ចំនុចនៅក្នុងបទបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោមនេះ រួមជាមួយកិច្ចព្រមព្រៀង និងពាក្យស្នើសុំកាតឥណទានត្រូវបានចាត់ទុកជាកិច្ចសន្យា កាតឥណទានដែលធ្វើឡើងដោយអ្នកផ្តល់កាត និងអ្នកប្រើប្រាស់កាត (កិច្ចសន្យា) ។ ការចុះហត្ថលេខានៅលើពាក្យស្នើសុំ និងកិច្ចព្រមព្រៀងគឺជាការបញ្ជាក់អំពីការយល់ព្រមរបស់អ្នកផ្តល់កាតនិងអ្នកប្រើប្រាស់ក្នុងការប្រតិបត្តិតាមបទបញ្ញត្តិ និងលក្ខខណ្ឌនានាទាក់ទងនឹងការផ្តល់កាតនិងការប្រើប្រាស់កាត ។

អ្នកផ្តល់កាតយល់ព្រមឱ្យអ្នកប្រើប្រាស់កាតធ្វើប្រតិបត្តិការស្ថិតក្នុងចំនួនកម្រិតឥណទានមួយដែលបានយល់ព្រមដោយភាគីទាំងពីរយោងទៅលើបទបញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ចសន្យា ។

អ្នកប្រើប្រាស់កាតត្រូវអាន និងពិចារណាដោយយកចិត្តទុកដាក់ចំពោះលក្ខខណ្ឌនានាមុនពេលចាប់ផ្តើមប្រើប្រាស់កាត ។

## 1. ការពន្យល់អំពីលក្ខខណ្ឌ

(1) កាតបន្ទាប់បន្សំគឺជាកាតឥណទានបន្ថែមដោយប្រើគណនីតែមួយដូចគ្នាជាមួយអ្នកប្រើប្រាស់កាតចម្បងដែលត្រូវបានផ្តល់ជូនដល់អ្នកមានសិទ្ធិប្រើប្រាស់ដើម្បីប្រើប្រាស់ទៅតាមការកំណត់របស់អ្នកប្រើប្រាស់កាតចម្បង ។

(2) អ្នកប្រើប្រាស់កាតបន្ទាប់បន្សំគឺជាបុគ្គលទាំងឡាយណាដែលអ្នកប្រើប្រាស់កាតចម្បងបានអនុញ្ញាតឱ្យប្រើប្រាស់កាតបន្ទាប់បន្សំដែលផ្តល់ឱ្យដោយអ្នកផ្តល់កាត ។ អ្នកប្រើប្រាស់កាតបន្ទាប់បន្សំត្រូវទទួលខុសត្រូវរួមគ្នា និងរៀងខ្លួនចំពោះប្រតិបត្តិការដែលកើតមានឡើង ការប្រាក់ ថ្លៃឈ្នួល និងការចំណាយពាក់ព័ន្ធនឹងគណនី ។

(3) អ្នកដាក់ពាក្យស្នើសុំ គឺជាបុគ្គលដែលចង់ក្លាយជាអ្នកប្រើប្រាស់កាតថ្មីមួយ ។

(4) ពាក្យស្នើសុំ និងកិច្ចព្រមព្រៀង (ហៅថា ពាក្យស្នើសុំ) គឺជាលិខិតដែលទាមទារឱ្យមានការបំពេញព័ត៌មានគ្រប់គ្រាន់ហើយដាក់ជូនឱ្យអ្នកផ្តល់កាតសម្រេចយល់ព្រមទទួល អ្នកដាក់ពាក្យស្នើសុំជាអ្នកប្រើប្រាស់កាត ហើយពាក្យស្នើសុំនេះត្រូវបានចាត់ទុកជាផ្នែកមួយនៃកិច្ចសន្យា ។

(5) បំណុលគឺជាចំនួនទឹកប្រាក់ដែលផ្តល់ជូននៅក្នុងកាត ហើយអ្នកប្រើប្រាស់កាតត្រូវទូទាត់សងមកអ្នកផ្តល់កាតវិញឱ្យបាន ឬនៅថ្ងៃដែលបានកំណត់រួមមានចំនួនបំណុលអប្បបរមា ថ្លៃឈ្នួលលើចំនួនទឹកប្រាក់លើសកំណត់ និងថ្លៃផ្សេងៗទៀតដែលមានការពាក់ព័ន្ធនឹងគណនី ។

(6) ម៉ាស៊ីន ATM គឺជាម៉ាស៊ីនដែលអ្នកប្រើប្រាស់កាតអាចដកប្រាក់ ។

(7) ការផ្ទេរសមតុល្យ គឺជាការផ្ទេរប្រាក់ទៅគណនីឥណទានផ្សេងទៀតរបស់លោកអ្នកដែលមិនមែនជាគណនីឥណទានរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។

(8) ថ្ងៃធ្វើការគឺជាថ្ងៃដែលមិនរាប់បញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យជាតិនានានៅក្នុងប្រទេសកម្ពុជា ។

(9) អ្នកប្រើប្រាស់កាតរួមមានអ្នកប្រើប្រាស់កាតចម្បង និង/ឬ អ្នកប្រើប្រាស់កាតរង ។ នៅក្នុងលក្ខខណ្ឌបានបញ្ជាក់ថា អ្នកប្រើប្រាស់កាតអាចជាអ្នកប្រើប្រាស់កាតចម្បង ឬជាអ្នកប្រើប្រាស់កាតរង ឬក៏ទាំងអ្នកប្រើប្រាស់កាតចម្បង និងអ្នកប្រើប្រាស់កាត រង ។

(10) អ្នកផ្តល់កាតគឺជា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ព្រមទាំងក្រុមហ៊ុនដែលមានសិទ្ធិគ្រប់គ្រងបន្ត និងក្រុមហ៊ុនដែលទទួលបានសិទ្ធិគ្រប់គ្រង ។

(11) សមតុល្យបំណុលដែលមាននៅក្នុងកាត (ហៅថា សមតុល្យបំណុល) គឺជាចំនួនបំណុលសរុបរបស់គណនីរួមមានទឹកប្រាក់ទាំងអស់ដែលបានធ្វើប្រតិបត្តិការថ្លៃសេវាកម្ម និងការប្រាក់នានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់កាត ។

(12) ប្រតិបត្តិការសាច់ប្រាក់ គឺជាការប្រើប្រាស់កាត (ដោយអ្នកប្រើប្រាស់កាត) ដើម្បីដកសាច់ប្រាក់ពីម៉ាស៊ីន ATM ធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត ។

(13) ការធានារបស់ក្រុមហ៊ុន គឺជាការធានាចំពោះកាតព្វកិច្ចរបស់អ្នកប្រើប្រាស់កាតតាមលក្ខខណ្ឌនៃកិច្ចសន្យាដោយក្រុមហ៊ុននោះធ្វើជាភាគីទី 3 នៃកិច្ចសន្យា ។

(14) កាតឥណទាន (ហៅថា កាត) គឺជាកាតឥណទានធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលអ្នកផ្តល់កាតបានផ្តល់ឱ្យអ្នកប្រើប្រាស់កាត ។

(15) គណនីកាតឥណទាន (ហៅថា គណនី) គឺជាគណនីដែលអ្នកផ្តល់កាតបើកឡើងដោយផ្អែកតាមកិច្ចសន្យាក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រតិបត្តិការដែលធ្វើឡើងដោយកាត ។ អ្នកប្រើប្រាស់កាតរងក៏ត្រូវស្ថិតនៅក្នុងគណនីតែមួយដូចគ្នានឹងអ្នកប្រើប្រាស់កាតចម្បងដែរ ។

(16) កិច្ចសន្យាកាតឥណទាន (ហៅថា កិច្ចសន្យា) រួមមានកិច្ចសន្យាដែលបានសរសេរអំពីលក្ខខណ្ឌនានាព្រមទាំងពាក្យស្នើសុំដែលបានចុះហត្ថលេខា ។

(17) ចំនួនកម្រិតឥណទាន (ហៅថា ចំនួនកំណត់) គឺជាចំនួនឥណទានអតិបរមានៅក្នុងកាតដែលអ្នកផ្តល់កាតបានយល់ព្រម ។

(18) គណនីប្រាក់បញ្ញើ៖ អ្នកប្រើប្រាស់កាតត្រូវផ្តល់គណនី ប្រាក់បញ្ញើ គណនីប្រាក់សន្សំ និង/ឬគណនីប្រាក់បញ្ញើមានកាលកំណត់ដើម្បីជាការធានាបំណុលរបស់អ្នកប្រើប្រាស់កាត តាមលក្ខខណ្ឌនៃកិច្ចសន្យានេះ ។

(19) កាលបរិច្ឆេទបំណុលគឺជាថ្ងៃដែលអ្នកប្រើប្រាស់កាតត្រូវទូទាត់បំណុល ឬចំនួនទឹកប្រាក់អប្បបរមា ។

(20) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់៖ គឺជាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ព្រមទាំងក្រុមហ៊ុនដែលមានសិទ្ធិគ្រប់គ្រងបន្ត និងក្រុមហ៊ុនដែលទទួលបានតែងតាំង ។

(21) ពាណិជ្ជករ (ហៅថា ពាណិជ្ជករ) គឺជាអង្គភាព ឬបុគ្គលដែលបានផ្តល់សិទ្ធិឱ្យ

ទទួលយកកាតជាមធ្យោបាយទូទាត់ថ្លៃទំនិញ និង/ ឬសេវាកម្ម។

(22) ចំនួនប្រាក់បំណុលអប្បបរមា (ហៅថា ចំនួនបំណុលអប្បបរមា) គឺជាចំនួនអប្បបរមានៃបំណុលរបស់កាតដែលបានបង្ហាញនៅក្នុងរបាយការណ៍ដោយអ្នកប្រើប្រាស់កាតត្រូវបង់ប្រាក់ទូទាត់ឱ្យបានមុន ឬនៅថ្ងៃកំណត់។

(23) ចំនួនលើសកម្រិតឥណទាន គឺជាសមតុល្យបំណុល ដែលលើសចំនួនកំណត់របស់ឥណទាន។

(24) អ្នកប្រើប្រាស់កាតចម្បងគឺជាបុគ្គលដែលប្រើឈ្មោះរបស់ខ្លួនបើកគណនី និងទទួលខុសត្រូវចំពោះប្រតិបត្តិការទាំងអស់រួមទាំង ថ្លៃសេវាកម្ម និងថ្លៃផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងគណនី។

(25) ប្រតិបត្តិការលក់ គឺជាការប្រើប្រាស់កាត (ដោយអ្នកប្រើប្រាស់កាត) ដើម្បីទូទាត់ ថ្លៃទំនិញ និង/ ឬសេវាកម្មផ្សេងៗ។

(26) សាច់ប្រាក់តម្កល់ គឺជាសាច់ប្រាក់ ឬកិច្ចសន្យាហិរញ្ញវត្ថុនានាដែលបានយល់ព្រមជាលាយលក្ខណ៍អក្សរដោយអ្នកផ្តល់កាតដែលអ្នកប្រើប្រាស់កាតបានផ្តល់ឱ្យដើម្បីធានាដល់ការទូទាត់បំណុលទាំងអស់របស់អ្នកប្រើប្រាស់កាតតាមកិច្ចសន្យា។

(27) របាយការណ៍គណនី (ហៅថា របាយការណ៍) គឺជាឯកសារសង្ខេបដែលអ្នកផ្តល់កាតចេញឱ្យអ្នកប្រើប្រាស់កាត។ របាយការណ៍នេះនិយាយអំពីប្រតិបត្តិការនានា ការប្រាក់ ថ្លៃសេវាកម្ម ការចំណាយ ការកែសម្រួលនានា (បើមាន) និងចំនួនអប្បបរមាទាក់ទងនឹងគណនីរបស់អ្នកប្រើប្រាស់កាត។

(28) ប្រតិបត្តិការៈ រួមមានប្រតិបត្តិការលក់ និងប្រតិបត្តិការសាច់ប្រាក់។

(29) ការបញ្ឈប់ គឺជាការផ្អាកបណ្តោះអាសន្ន បញ្ឈប់ លុបចោលការប្រើប្រាស់កាតរួមទាំងសិទ្ធិ និងលក្ខណៈពិសេសរបស់កាតផងដែរ។

(30) “លោកអ្នក” មានន័យថា លើកលែងតែមានការបញ្ជាក់ដោយឡែកជាអ្នកប្រើប្រាស់កាតនិងអ្នកទទួលបានសិទ្ធិប្រើប្រាស់ (“របស់លោកអ្នក” មានអត្ថន័យទាក់ទងនឹងពាក្យនេះ) ។

## ការផ្តល់កាត

### 2. កាតព្វកិច្ចទូទាត់របស់អ្នកប្រើប្រាស់កាត

អ្នកប្រើប្រាស់កាត រួមទាំងអ្នកប្រើប្រាស់កាតចម្បង និងអ្នកប្រើប្រាស់កាតបន្ទាប់បន្សំ ត្រូវទទួលខុសត្រូវរួមគ្នា និងរៀងខ្លួនចំពោះការទូទាត់ប្រតិបត្តិការនានា ការប្រាក់ ថ្លៃសេវាកម្ម និងការចំណាយពាក់ព័ន្ធនិងគណនីតាមរយៈការប្រើប្រាស់កាត ប៉ុន្តែមិនកំណត់ថ្លៃសេវាកម្មដែលមិនអាចដកយកវិញ ពន្ធអាករនានាដែលមានចែងក្នុងច្បាប់ លុះត្រាតែការទូទាត់គ្រប់ចំនួនដល់អ្នកផ្តល់កាតត្រូវបានធ្វើឡើងដោយមិនមានការស្នើសុំចុះហត្ថលេខាលើវិក្កយបត្រនិងឯកសារយោងនានា។

អ្នកប្រើប្រាស់កាតនៅតែមានកាតព្វកិច្ចទូទាត់បំណុលរបស់ខ្លួននៅក្នុងករណីមានការចេញកាតថ្មី ឬមានការជំនួសកាតដោយអ្នកផ្តល់កាតនិងនៅក្នុងករណីបញ្ឈប់ដោយហេតុផល

ណាមួយផងដែរ ។

ដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អ្នកប្រើប្រាស់កាត អ្នកផ្តល់កាតរក្សាសិទ្ធមានសិទ្ធិគ្រប់គ្រាន់ក្នុងការ៖

- យល់ព្រម ឬបដិសេធផ្តល់កាតដល់អ្នកប្រើប្រាស់កាតទោះបីជាអ្នកប្រើប្រាស់កាតបំពេញលក្ខខណ្ឌនានាក្នុងការចេញកាតដែលកំណត់ដោយអ្នកផ្តល់កាតក៏ដោយ
- បដិសេធ ឬយល់ព្រមលើប្រតិបត្តិការទោះបីជាប្រតិបត្តិការនោះស្ថិតនៅក្នុងចំនួនកម្រិតដែលអាចផ្តល់ឱ្យក៏ដោយ
- បញ្ឈប់ដំណើរការកាតរបស់អ្នកប្រើប្រាស់កាតបានគ្រប់ពេល
- បង្កើន ឬបន្ថយកម្រិតឥណទាន
- បដិសេធក្នុងការផ្តល់កាតម្តងទៀត ផ្តល់កាតថ្មី កាតជំនួស ឬពន្យារពេលកំណត់របស់កាត និង
- កែតម្រូវ ផ្លាស់ប្តូរ កំណត់ ឬលុបចោលសេវាកម្ម និងអត្ថប្រយោជន៍នានា ដែលទាក់ទងនឹងកាត និងគណនីរបស់អ្នកប្រើប្រាស់ ។

អ្នកផ្តល់កាតមិនទទួលខុសត្រូវចំពោះការទាមទារសងថ្លៃការខូចខាតណាមួយដែលធ្វើឡើងដោយអ្នកប្រើប្រាស់កាតក្នុងករណីដែលអ្នកផ្តល់កាតមិនយល់ព្រមអនុញ្ញាតចំពោះប្រតិបត្តិការណាមួយពីគណនីរបស់អ្នកប្រើប្រាស់កាត និង/ ឬប្រសិនបើពាណិជ្ជករមិនយល់ព្រមទទួលយកកាតទោះបីប្រតិបត្តិការនោះស្ថិតនៅក្នុងចំនួនកម្រិតដែលអាចផ្តល់ឱ្យក៏ដោយ ។ អ្នកផ្តល់កាតអាចកម្រិតចំនួនប្រតិបត្តិការប្រចាំថ្ងៃ និង/ឬចំនួនទឹកប្រាក់ប្រតិបត្តិការប្រចាំថ្ងៃ ។

ប្រសិនបើអ្នកផ្តល់កាតរកឃើញថាមានសកម្មភាពគួរឱ្យសង្ស័យ ឬមិនធម្មតាណាមួយទាក់ទងនឹងគណនី អ្នកផ្តល់កាតអាចស្នើសុំឱ្យអ្នកប្រើប្រាស់កាតទាក់ទងមកកាន់អ្នកផ្តល់កាត និង/ ឬផ្អាកជា បណ្តោះអាសន្ននូវសិទ្ធិខ្លះ ឬសិទ្ធិទាំងអស់ក្នុងការប្រើប្រាស់កាតលុះត្រាតែអ្នកផ្តល់កាតពិនិត្យផ្ទៀងផ្ទាត់រួចរាល់សិន ។

ដោយផ្អែកតាមការសម្រេចចិត្តរបស់ខ្លួន អ្នកផ្តល់កាតយល់ព្រមក្នុងការអនុញ្ញាតចំពោះប្រតិបត្តិការនានាដែលមានចំនួនទឹកប្រាក់សរុបលើសពីចំនួនកម្រិត ។ ហានិភ័យណាមួយដែលអាចកើតឡើងជាបន្ទុករបស់អ្នកប្រើប្រាស់កាត ។

## ការប្រើប្រាស់កាត

### 3. ការហាមឃាត់ក្នុងការប្រើប្រាស់កាត

អ្នកប្រើប្រាស់កាតយល់ព្រមមិនប្រើកាតក្នុងគោលបំណងល្មើសច្បាប់ណាមួយ រួមទាំងការបំពានច្បាប់ស្តីពីការប្តូរ វិនិយោគ និងការប្រើប្រាស់រូបិយប័ណ្ណ ។

### 4. ប្រតិបត្តិការទិញទំនិញ

អ្នកប្រើប្រាស់កាតអាចប្រើកាតដើម្បីធ្វើប្រតិបត្តិការលើការទិញទំនិញ (ទូទាត់ថ្លៃទំនិញ/សេវាកម្ម) នៅក្នុងហាងរបស់ពាណិជ្ជករណាមួយ ។ អ្នកប្រើប្រាស់កាតត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវតាមការស្នើសុំរបស់អ្នកផ្តល់កាតដើម្បីពិចារណាយល់ព្រមចំពោះ

ប្រតិបត្តិការ។ អ្នកផ្តល់កាតមានសិទ្ធិកត់ត្រាផ្នែកឥណពន្ធ នៃគណនីតាមចំនួនទឹកប្រាក់ដែលអ្នកប្រើប្រាស់កាតបានធ្វើប្រតិបត្តិការ។

អ្នកផ្តល់កាតមិនទទួលខុសត្រូវចំពោះការផ្តល់ជូន ឬគុណភាពរបស់ទំនិញ/ សេវាកម្មដែលបានធ្វើការទូទាត់តាមរយៈប្រតិបត្តិការទិញទំនិញ។ ការតវ៉ាណាមួយទាក់ទងនឹងបញ្ហានេះជាបន្ទុកអ្នកប្រើប្រាស់កាត និងពាណិជ្ជករ។

អ្នកប្រើប្រាស់កាតទទួលខុសត្រូវរាល់ការតវ៉ាលើការទូទាត់និងបញ្ហាពាក់ព័ន្ធនានាដោយផ្ទាល់ជាមួយពាណិជ្ជករ។

## 5. ប្រតិបត្តិការសាច់ប្រាក់

អ្នកប្រើប្រាស់កាតអាចធ្វើប្រតិបត្តិការដកប្រាក់តាមរយៈម៉ាស៊ីន ATM និងតាមក្រុមហ៊ុនដែលបានចុះកិច្ចព្រមព្រៀង។ ក្នុងករណីធ្វើប្រតិបត្តិការដកប្រាក់ អ្នកប្រើប្រាស់កាតត្រូវប្រើលេខកូដសម្ងាត់ផ្ទាល់ខ្លួន (PIN) ដែលបានផ្តល់ដោយអ្នកផ្តល់កាត។ ព័ត៌មានបន្ថែមស្តីអំពីចំនួនកំណត់ប្រតិបត្តិការសាច់ប្រាក់ សូមមើលខិតប័ណ្ណព័ត៌មានថ្លៃសេវាកម្ម និងថ្លៃផ្សេងៗ។

រាល់ប្រតិបត្តិការសាច់ប្រាក់ទាំងអស់ដែលធ្វើឡើងដោយកាតត្រូវបានចាត់ទុក និងទទួលស្គាល់ថាពិតជាបានធ្វើឡើងដោយប្រើប្រាស់កាត។ អ្នកប្រើប្រាស់កាតមិនចាំបាច់ត្រូវការឱ្យបង្ហាញឯកសារយោងដែលទាក់ទងនឹងប្រតិបត្តិការណាមួយរបស់កាតឡើយ និងត្រូវទទួលស្គាល់ថារបាយការណ៍របស់អ្នកផ្តល់កាតពិតជាត្រឹមត្រូវ។

អ្នកផ្តល់កាតរក្សាសិទ្ធិក្នុងការកម្រិតចំនួនទឹកប្រាក់របស់ប្រតិបត្តិការដកប្រាក់នីមួយៗ និង/ ឬចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការដកប្រាក់នៅលើកាតក្នុង 1 ថ្ងៃដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អ្នកប្រើប្រាស់កាត។ ការកំណត់ និង/ ឬការកែប្រែចំនួនទឹកប្រាក់ជាការសម្រេចចិត្តរបស់អ្នកផ្តល់កាតតែម្នាក់គត់។

## 6. ការប្រើប្រាស់លេខសម្ងាត់ផ្ទាល់ខ្លួន

អ្នកប្រើប្រាស់កាតមិនត្រូវផ្តល់កាត ឬបង្ហាញលេខកូដសម្ងាត់ (PIN) ដល់បុគ្គលណាមួយដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់កាតឡើយ។ នៅក្នុងកាលៈទេសៈទាំងនេះ អ្នកប្រើប្រាស់កាតត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះប្រតិបត្តិការ ឬការគិតថ្លៃណាមួយដែលត្រូវបានធ្វើឡើងតាមរយៈកាត។

អ្នកប្រើប្រាស់កាតត្រូវជូនដំណឹងដល់អ្នកផ្តល់កាតជាបន្ទាន់ប្រសិនបើកាតបានបាត់បង់ ត្រូវគេលួច ឬក៏ប្រសិនបើមានការសង្ស័យថាលេខកូដសម្ងាត់មានគេដឹង ហើយអ្នកប្រើប្រាស់កាតត្រូវទទួលបន្ទុករាល់ថ្លៃសេវាកម្ម និងថ្លៃផ្សេងៗទៀតដែលបានបញ្ជាក់ដោយអ្នកផ្តល់កាត នឹងបានផ្តល់ជាព័ត៌មានដល់អ្នកប្រើប្រាស់កាត។

## 7. របាយការណ៍

អ្នកផ្តល់កាតនឹងផ្តល់របាយការណ៍ប្រចាំខែដល់អ្នកប្រើប្រាស់កាតទៅតាមអាសយដ្ឋានដែលបញ្ជាក់ដោយអ្នកប្រើប្រាស់កាត។ របាយការណ៍ត្រូវបានចាត់ទុកថាត្រឹមត្រូវ លើកលែងតែមានការជូនដំណឹងពីអ្នកប្រើប្រាស់កាតអំពីភាពមិនត្រឹមត្រូវក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍។ រាល់បញ្ហាទាក់ទងនឹងចំនួនតួលេខដែលមានក្នុងរបាយការណ៍ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវតែទទួលបានដោយអ្នកផ្តល់កាតក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍។ ផ្អែកតាមការសម្រេចចិត្ត

របស់ខ្លួនប្រសិនបើអ្នកផ្តល់កាតសម្រេចចិត្តថាចំនួនតួលេខដែលមានបញ្ហានោះ គឺជាកំហុសបច្ចេកទេស និងមិនត្រូវគិតថ្លៃពីអ្នកប្រើប្រាស់កាត ចំនួននោះនឹងត្រូវបានកត់ត្រាកែសម្រួលផ្នែកឥណទាននៅសមតុល្យបំណុល។ ចំនួនបំណុលអប្បបរមា និង/ ឬចំនួនបំណុលផ្សេងៗទៀត នឹងត្រូវទូទាត់ដោយអ្នកប្រើប្រាស់កាត ដដែល។

ទោះជាមានចំណុចខ្វះខុស មិនមានវិក្កយបត្រ ឬវិក្កយបត្ររបាយការណ៍មានការយឺតយ៉ាវក៏ដោយ ក៏មិនអាចជាមូលហេតុក្នុងការជួយសម្រាលកាតព្វកិច្ចរបស់អ្នកប្រើប្រាស់កាតក្នុងការទូទាត់ចំនួនបំណុលអប្បបរមាក្នុងគណនីតាមកាលកំណត់នៅក្នុងរបាយការណ៍បានដែរ។

អ្នកផ្តល់កាតនឹងមិនផ្តល់របាយការណ៍ប្រចាំខែដល់អ្នកប្រើប្រាស់កាតទៅតាមអាសយដ្ឋានដែលបញ្ជាក់ដោយអ្នកប្រើប្រាស់កាត បើសិនជា៖

- សមតុល្យនៅចុងកាលបរិច្ឆេទនៃគណនីកាតឥណទានមានចំនួនតិចជាង 10 ដុល្លារ (ឬចំនួនណាមួយកំណត់ដោយច្បាប់) ហើយមិនមានចំនួនទឹកប្រាក់ណាមួយដែលត្រូវបានកត់ត្រាទៅក្នុងគណនីចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ពេលមុន (លើកលែងតែកំណត់ត្រាផ្នែកឥណពន្ធសម្រាប់វិក្កយបត្រពន្ធ ឬការគិតថ្លៃផ្សេងរបស់រដ្ឋាភិបាល ឬក៏ការដកប្រាក់)
- អ្នកប្រើប្រាស់កាតមិនបានបំពេញតាមកិច្ចសន្យាក្នុងអំឡុងពេលនៃកាលបរិច្ឆេទនៃរបាយការណ៍ និងនៅក្នុងអំឡុងពេលនៃកាលបរិច្ឆេទពីរចុងក្រោយ ហើយអ្នកផ្តល់កាតបានកំណត់មិនផ្តល់ និងមិនបានផ្តល់ឥណទានបន្ថែមទៀត
- អ្នកប្រើប្រាស់កាតបានទទួលមរណភាព ឬមិនមានប្រាក់ទូទាត់សង ហើយតំណាងផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់កាត ឬក្រុមប្រឹក្សាក្ស័យធនមិនបានស្នើសុំរបាយការណ៍គណនី ឬ
- អ្នកផ្តល់កាតត្រូវបានលើកលែង ដោយច្បាប់ពីការផ្ញើរបាយការណ៍ទៅអ្នកប្រើប្រាស់កាត។

នៅក្នុងអនុប្រយោគទី 7 នេះមានបំណងបញ្ជាក់ថា គណនីដែលមានសមតុល្យវិជ្ជមាន (ឥណទាន) នៅពេលបិទកាលបរិច្ឆេទនៃរបាយការណ៍នឹងត្រូវចាត់ទុកថាជាគណនីដែលមានសមតុល្យតិចជាងចំនួន 10 ដុល្លារ។

ការកំណត់កាលបរិច្ឆេទគឺជាការសម្រេចចិត្តរបស់អ្នកផ្តល់កាត និងត្រូវបានជូនដំណឹងដល់អ្នកប្រើប្រាស់កាតនៅពេលផ្តល់កាត។ របាយការណ៍នឹងត្រូវបានចាត់ទុកថាពិតជាត្រូវបានទទួលដោយអ្នកប្រើប្រាស់កាតក្នុងអំឡុងខែប្រតិបត្តិការលើកលែងតែមានការជូនដំណឹងពីអ្នកប្រើប្រាស់កាតអំពីការមិនបានទទួលរបាយការណ៍ក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍។

## 8. ភាពជាម្ចាស់កម្មសិទ្ធនៃកាត

កាតគឺជាទ្រព្យសម្បត្តិរបស់អ្នកផ្តល់កាត ហើយអ្នកប្រើប្រាស់កាតមិនអាចផ្ទេរទៅអ្នកផ្សេងបានឡើយ។ ការចុះហត្ថលេខានៅលើកាតត្រូវតែធ្វើឡើងភ្លាមៗដោយបុគ្គលដែលត្រូវផ្តល់កាតឱ្យ ហើយសុពលភាពរបស់កាតចាប់ផ្តើមពីថ្ងៃដែលផ្តល់កាត ឬថ្ងៃដែលចេញកាតឱ្យថ្មីរហូតដល់ថ្ងៃចុងក្រោយនៃខែផុតកំណត់សុពលភាពដែលមានបញ្ជាក់នៅលើកាត។

អ្នកផ្តល់កាតមានសិទ្ធបញ្ឈប់ការផ្តល់កាតណាមួយ និងបញ្ឈប់ការប្រើប្រាស់កាតបានគ្រប់ពេល មិនថាក្នុងមូលហេតុណាមួយឡើយដោយមិនចាំបាច់ជូនដំណឹងដល់អ្នកប្រើប្រាស់កាតជាមុនទេ។ នៅក្នុងកាលៈទេសៈនេះអ្នកប្រើប្រាស់កាតយល់ព្រមប្រគល់កាតត្រឡប់មកវិញហើយអ្នកផ្តល់កាត ឬស្ថាប័នណាមួយដែលទទួលបានសិទ្ធិពីអ្នកផ្តល់កាតក៏មានសិទ្ធិរឹបអូសយកមកវិញផងដែរ។ ដោយផ្អែកតាមការបញ្ឈប់នេះ សមតុល្យគណនីរួមទាំងថ្លៃសេវាកម្ម និងការប្រាក់ទាំងអស់ត្រូវតម្រូវឱ្យធ្វើការទូទាត់ភ្លាមដោយគ្មានការតវ៉ា ឬជូនដំណឹងជាមុនពីអ្នកផ្តល់កាត។

អ្នកប្រើប្រាស់កាតមិនត្រូវប្រើកាតបន្តទៀតឡើយ បន្ទាប់ពីកាតអស់សុពលភាព ឬបន្ទាប់ពីការបញ្ឈប់កិច្ចសន្យា និងមិនត្រូវអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់កាតនោះឡើយ ទោះក្នុងមូលហេតុណាក៏ដោយបន្ទាប់ពីមានហេតុការណ៍នេះ។ ការបន្តប្រើប្រាស់កាតនោះទៀត អ្នកប្រើប្រាស់កាតនឹងត្រូវចាត់ទុកថាបានប្រព្រឹត្តសកម្មភាពលួចបន្លំ។

អ្នកផ្តល់កាតអាចកែប្រែលេខកាត និង/ ឬកាលបរិច្ឆេទផុតកំណត់នៅពេលផ្តល់កាតថ្មី ឬផ្តល់កាត ជំនួស។ អ្នកប្រើប្រាស់កាតត្រូវទទួលខុសត្រូវជូនដំណឹងអំពីការផ្លាស់ប្តូរនេះទៅកាន់ភាគីណាមួយដែលអ្នកប្រើប្រាស់កាតបានចាត់ចែងក្នុងការទូទាត់។ អ្នកផ្តល់កាតនឹងមិនទទួលខុសត្រូវចំពោះអ្នកប្រើប្រាស់កាត រាល់ផលវិបាក ឬការខូចខាតណាមួយដែលកើតឡើងដោយសារតែប្រតិបត្តិការត្រូវបានបដិសេធឡើយ ទោះបីជាបណ្តាលមកពីលេខកាតមុន ឬមកពីអ្វីផ្សេងទៀតក៏ដោយ។

កាតដែលបានបាត់បង់ ឬត្រូវចោរលួចហើយត្រូវបានរកឃើញវិញដោយអ្នកប្រើបាស់កាតនោះអ្នកប្រើប្រាស់កាតត្រូវប្រគល់ឱ្យអ្នកផ្តល់កាតវិញ។

អ្នកប្រើប្រាស់កាតចម្បងអាចបិទគណនីបានគ្រប់ពេលវេលាទាំងអស់ ដោយគ្រាន់តែជូនដំណឹងមកអ្នកផ្តល់កាតជាលាយលក្ខណ៍អក្សរ។ សមតុល្យគណនីរួមទាំងថ្លៃសេវាកម្ម និងការប្រាក់ទាំងអស់ទាក់ទងនឹងប្រតិបត្តិការត្រូវតម្រូវឱ្យធ្វើការទូទាត់ភ្លាមៗដោយគ្មានការតវ៉ា ឬជូនដំណឹងជាមុន។

បើគណនីបានបិទដោយអ្នកប្រើប្រាស់ចម្បងការប្រើប្រាស់កាតដ៏ទៃទៀតនឹងមិនត្រូវបានអនុញ្ញាតឡើយ។

## 9. ការណែនាំអ្នកប្រើប្រាស់កាត

អ្នកប្រើប្រាស់កាតផ្តល់សិទ្ធិដល់អ្នកផ្តល់កាតដើម្បីធ្វើសកម្មភាពនានាដែលអ្នកផ្តល់កាតយល់ឃើញថាត្រឹមត្រូវ ដោយផ្អែកតាមការណែនាំដែលអ្នកប្រើប្រាស់កាតបានផ្តល់ជូនដល់អ្នកផ្តល់កាត។ ការណែនាំរបស់អ្នកប្រើប្រាស់កាតអាចត្រូវបានជូនដំណឹងរៀងរាល់ពេលដោយអ្នកប្រើប្រាស់កាតទៅអ្នកផ្តល់កាតតាមរយៈអ៊ីម៉ែល ទូរស័ព្ទ ទូរសារ ឬតេឡេ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់កាតរក្សាសិទ្ធិទាមទារឱ្យមានការបញ្ជាក់អំពីការណែនាំនានា ឬការបំពេញជាទម្រង់បែបបទជាក់លាក់ណាមួយ ឬក៏តម្រូវឱ្យសរសេរជាលាយលក្ខណ៍អក្សរជាមុនទើបអ្នកផ្តល់កាតអនុវត្តតាមការណែនាំនោះ។ អ្នកផ្តល់កាតត្រូវបានផ្តល់សិទ្ធិដើម្បីអនុវត្តការណែនាំរបស់អ្នកប្រើប្រាស់កាត និងចាត់វិធានការនានាដែលទាក់ទងនឹងការណែនាំ។

## 10. ការកែប្រែព័ត៌មាន

អ្នកប្រើប្រាស់កាតត្រូវជូនដំណឹងដល់អ្នកផ្តល់កាតជាបន្ទាន់ក្នុងករណីមានការផ្លាស់ប្តូរ

ព័ត៌មានរបស់ខ្លួនរួមទាំងការប្តូរអាសយដ្ឋាន លេខទូរស័ព្ទ ឬអាសយដ្ឋាន អ៊ីម៉ែល និង មធ្យោបាយនានា ក្នុងការទាក់ទងដែលអ្នកផ្តល់កាតអាចទាក់ទងមកអ្នកប្រើប្រាស់កាតរួមទាំងមធ្យោបាយដែលមិនមានបញ្ជាក់នៅក្នុងពាក្យស្នើសុំ ។

ប្រសិនបើអ្នកផ្តល់កាតមិនអាចរកអាសយដ្ឋានផ្ញើប័ណ្ណទូទាត់ប្រាក់ឃើញតាមរយៈការផ្ញើសំបុត្រ ឬការបញ្ជូនដោយផ្ទាល់ នោះអ្នកផ្តល់កាតរក្សាសិទ្ធិប្រើប្រាស់អាសយដ្ឋានផ្សេងទៀតដែលបានផ្តល់ ឱ្យអ្នកប្រើប្រាស់កាត ។

អ្នកប្រើប្រាស់កាតយល់ព្រមឱ្យអ្នកផ្តល់កាតផ្ញើព័ត៌មានទំនាក់ទំនងទៅកាន់អាសយដ្ឋានផ្ញើប័ណ្ណទូទាត់ ឬប្រសិនបើមិនអាចទាក់ទងតាមអាសយដ្ឋាននេះបាន ការផ្ញើទៅកាន់អាសយដ្ឋានផ្សេងទៀតដែលបានផ្តល់ឱ្យដោយអ្នកប្រើប្រាស់កាតនឹងត្រូវបានចាត់ទុកថាបានទទួលដោយអ្នកប្រើប្រាស់កាតក្នុងរយៈពេល 10 ថ្ងៃ ។

## 11. ការលើកលែង

កាតព្វកិច្ចបំណុលរបស់អ្នកប្រើប្រាស់កាតដែលមានចំពោះអ្នកផ្តល់កាតជាកាតព្វកិច្ចត្រូវបំពេញ ។ រាល់ជម្លោះណាមួយរវាងអ្នកប្រើប្រាស់កាតជាមួយស្ថាប័ន ឬបុគ្គលណាមួយនឹងមិនប៉ះពាល់ដល់កាតព្វកិច្ចបំណុលរបស់អ្នកប្រើប្រាស់កាតដែលមានចំពោះអ្នកផ្តល់កាតឡើយ ។

អ្នកផ្តល់កាតត្រូវរួចផុតពីការទទួលខុសត្រូវណាមួយចំពោះការខូចខាត ឬការខាតបង់ដែលអាចបណ្តាលមកពីអ្នកប្រើប្រាស់កាតក្នុងករណីដូចខាងក្រោម៖

- ពាណិជ្ជករមានការភាន់ច្រឡំទទួលយកការទូទាត់ដោយកាត ដោយសារហេតុផលណាមួយ
- ការមិនដំណើរការ កំហុស ការបែកបាក់ម៉ាស៊ីន ATM ណាមួយ និង/ ឬឧបករណ៍ណាមួយសម្រាប់ទទួលការទូទាត់ដោយកាត
- ការយឺតយ៉ាវ ឬពុំមានលទ្ធភាពក្នុងការអនុវត្តការទទួលខុសត្រូវតាមកិច្ចសន្យា ដោយសារការមិនដំណើរការម៉ាស៊ីនទិន្នន័យ ទំនាក់ទំនងប្រធានសក្តិ ឬហេតុការណ៍ណាមួយដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់អ្នកផ្តល់កាត ឬផលវិបាកនៃការលួចបន្លំ ឬក្លែងបន្លំ
- មិនមានលទ្ធភាពទទួលបានទិន្នន័យ និង/ ឬព័ត៌មានដែលជាប់ទាក់ទងនឹងកាត
- ការខូចខាត ឬភាពមិនប្រក្រតីនៃទំនិញនិងសេវាកម្មដែលអ្នកប្រើប្រាស់កាត ទិញ ឬប្រើ

អ្នកផ្តល់កាតត្រូវរួចពីការទទួលខុសត្រូវចំពោះការធ្វើឱ្យប៉ះពាល់កិត្តិយសកេរ្តិ៍ឈ្មោះរបស់អ្នកប្រើប្រាស់កាតក្នុងករណីដែលកាតត្រូវបានបដិសេធលុបចោល ឬក៏កាតត្រូវបានដកហូតពីអ្នកប្រើប្រាស់កាត ឬក៏កិច្ចសន្យាត្រូវបានបញ្ចប់ ។

## 12. កាតត្រូវបានបាត់បង់ ឬចោរលួច

ក្នុងករណីដែលកាតត្រូវបានចោរលួច ឬបាត់បង់អ្នកប្រើប្រាស់កាតត្រូវជូនដំណឹងមកអ្នកផ្តល់កាតជាបន្ទាន់ ។ អ្នកប្រើប្រាស់កាតអាចទទួលខុសត្រូវចំពោះប្រតិបត្តិការនានាដែលមិនមានការអនុញ្ញាតយល់ព្រមពីលោកអ្នកដែលជាអ្នកប្រើប្រាស់កាត (រួមទាំងការធ្វើ

ប្រតិបត្តិការតាមរយៈទូរស័ព្ទ ឬអ៊ីម៉ែល និងប្រតិបត្តិការតាមអ៊ិនធើណេត) ដែលកើតឡើងមុនពេលលោកអ្នកបានជូនដំណឹងមកអ្នកផ្តល់កាតអំពីការបាត់កាត ឬចោរលួចកាត។

ថ្លៃសេវាកម្មចេញកាតថ្មីដែលបានកំណត់ដោយអ្នកផ្តល់កាតអាចត្រូវបានគិតពីគណនីរបស់អ្នកប្រើប្រាស់កាត ដើម្បីទូទាត់ថ្លៃផ្សេងៗដែលទាក់ទងនឹងការចេញកាត។

## 13. ប្រតិបត្តិការបង្វិលប្រាក់សងវិញ

លោកអ្នកអាចត្រូវបានផ្តល់សិទ្ធិក្នុងការធ្វើប្រតិបត្តិការទទួលយកប្រាក់បង្វិលសងវិញនៅកន្លែង ដែលលោកអ្នកមានបញ្ហាជាមួយពាណិជ្ជករ។ ឧទាហរណ៍ លោកអ្នកអាចត្រូវបានផ្តល់សិទ្ធិដើម្បីធ្វើប្រតិបត្តិការទទួលយកប្រាក់បង្វិលសងវិញនៅពេលដែលពាណិជ្ជករមិនបានផ្តល់ឱ្យលោកអ្នកនូវទំនិញ ឬសេវាកម្មមានគុណភាពល្អតាមតម្លៃដែលលោកអ្នកបានចំណាយ។

## 14. រយៈពេលកំណត់នៃប្រតិបត្តិការបង្វិលប្រាក់សងវិញ

លោកអ្នកគួរតែជូនដំណឹងជាបន្ទាន់ដល់អ្នកផ្តល់កាតអំពីប្រតិបត្តិការដែលមានបញ្ហា។ មុខងារ ប្រព័ន្ធប្រតិបត្តិការរបស់កាតឥណទានបានកំណត់រយៈពេលផុតកំណត់សុពលភាពរបស់ប្រតិបត្តិការដែលអ្នកផ្តល់កាតមិនអាចបំពេញប្រតិបត្តិការបង្វិលប្រាក់សងជូនវិញបាន។ រយៈពេលកំណត់អប្បបរមា ជាទូទៅគឺ 75 ថ្ងៃបន្ទាប់ពីប្រតិបត្តិការដែលមានបញ្ហា ប៉ុន្តែរយៈពេលកំណត់ខ្លះអាចយូរជាងនេះ។ ប្រសិនបើលោកអ្នកមិនបានជូនដំណឹងមកអ្នកផ្តល់កាតទាន់ពេលទេ អ្នកផ្តល់កាតមិនអាចពិនិត្យផ្ទៀងផ្ទាត់មើលការតវ៉ារបស់លោកអ្នកទេ ហើយលោកអ្នកត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការនោះ។

លោកអ្នកទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់មើលដោយយកចិត្តទុកដាក់លើរបាយការណ៍គណនីរបស់លោកអ្នក។ អ្នកផ្តល់កាតមិនទទួលខុសត្រូវចំពោះការបាត់បង់នានា ប្រសិនបើ លោកអ្នក មិនបានស្នើសុំធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញនៅក្នុងរយៈពេលកំណត់។

## 15. ការបញ្ឈប់ដោយអ្នកប្រើប្រាស់កាត

ការបញ្ឈប់កិច្ចសន្យាត្រូវធ្វើឡើងតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់អ្នកប្រើប្រាស់កាតចម្បងដែលបញ្ជាក់អំពីគោលបំណងក្នុងការបិទគណនី និងទូទាត់សមតុល្យបំណុលរបស់គណនីរួមទាំងការទូទាត់បំណុលផ្សេងៗទៀត។ នៅពេលអ្នកប្រើប្រាស់កាតចម្បងបានបញ្ឈប់កិច្ចសន្យា ទាំងអ្នកប្រើប្រាស់កាតចម្បង និងអ្នកប្រើប្រាស់កាតបន្ទាប់បន្សំមិនអាចធ្វើប្រតិបត្តិការណាមួយទាក់ទងនឹងគណនីនេះទៀតទេ។ ការបញ្ឈប់នឹងមានប្រសិទ្ធភាពក្នុងរយៈពេល 5 ថ្ងៃនៃថ្ងៃធ្វើការ ឬតិចជាងនេះបន្ទាប់ពីលក្ខខណ្ឌខាងលើនៅក្នុងប្រយោគនេះត្រូវបានបំពេញរួចរាល់។

លិខិតធានាបំណុលសម្រាប់គណនីដែលបានផ្តល់ឱ្យដោយអ្នកប្រើប្រាស់កាតនឹងត្រូវបានទទួលយកក្នុងរយៈពេលអប្បបរមាចំនួន 30 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបញ្ឈប់។

## 16. ទំនាក់ទំនង

អ្នកប្រើប្រាស់កាតយល់ព្រមទទួលការទាក់ទងតាមរយៈទូរស័ព្ទពីអ្នកផ្តល់កាត ឬពីភាគីទីបីដែលទទួលបានសិទ្ធិពីអ្នកផ្តល់កាត។ អ្នកផ្តល់កាត ឬភាគីទីបីដែលទទួលបានសិទ្ធិអាចថតសម្លេងរាល់ទំនាក់ទំនងតាមទូរស័ព្ទរបស់អ្នកផ្តល់កាត។ អ្នកប្រើប្រាស់កាតយល់ព្រមឱ្យ

អ្នកផ្តល់កាត ឬឱ្យភាគីទីបីប្រើប្រាស់សម្លេងដែលបានថតនោះ ទោះក្នុងគោលបំណងណាមួយក៏ដោយ រួមទាំងប្រើប្រាស់ជាភស្តុតាងក្នុងការប្តឹង ការវិនិច្ឆ័យ និងការងាររដ្ឋបាល ។

## 17. ការជូនដំណឹងពីអ្នកផ្តល់កាត

ការជូនដំណឹងដែលបានផ្ញើដោយអ្នកផ្តល់កាតទៅឱ្យអ្នកប្រើប្រាស់កាតតាមការផ្ញើសំបុត្រ ការផ្ញើសារជាអក្សរ តេឡេ ទូរសារ អ៊ីម៉ែល ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតដោយប្រើអាសយដ្ឋានទំនាក់ទំនងដែលបានផ្តល់ឱ្យដោយអ្នកប្រើប្រាស់កាតនឹងត្រូវចាត់ទុកថាជាការផ្ញើជូនចំពោះអ្នកប្រើប្រាស់កាត ។ អ្នកផ្តល់កាតមិនទទួលខុសត្រូវចំពោះអ្នកប្រើប្រាស់កាតក្នុងករណីដែលព័ត៌មានមាននៅក្នុងការជូនដំណឹងអេឡិចត្រូនិកនេះត្រូវបានដឹងដោយអ្នកផ្សេងក្រៅពីអ្នកប្រើប្រាស់កាត ទោះបីតាមវិធីណាក៏ដោយ ។

## ចំនួនកម្រិតឥណទាន

## 18. ការលើសចំនួនកំណត់

អ្នកប្រើប្រាស់កាតត្រូវពិនិត្យជាប្រចាំនូវបំណុលសរុបរបស់ខ្លួនថាមិនត្រូវឱ្យលើសចំនួនកំណត់ក្នុងរយៈពេលជាក់លាក់មួយ ។ អ្នកប្រើប្រាស់កាតត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការ និងថ្លៃសេវាកម្មផ្សេងៗដែលបណ្តាលមកពីសមតុល្យបំណុលលើសចំនួនកំណត់ ។

អ្នកផ្តល់កាតរក្សាសិទ្ធិក្នុងការបដិសេធចំពោះប្រតិបត្តិការណាមួយផ្អាកសុពលភាពកាតរបស់អ្នកប្រើប្រាស់កាត និង/ ឬគិតថ្លៃសេវាកម្មលើសពីថ្លៃសេវាកម្មដែលបានកំណត់ដោយមិនចាំបាច់ជូនដំណឹងជាមុនប្រសិនបើមានការប្រើប្រាស់លើសចំនួនកម្រិតឥណទាន ។ ដោយអនុញ្ញាតយល់ព្រមឱ្យមានប្រតិបត្តិការណាមួយដែលនាំឱ្យសមតុល្យបំណុលលើសចំនួនទឹកប្រាក់កំណត់ នោះអ្នកផ្តល់កាតនឹងមិនបង្កើនចំនួនទឹកប្រាក់កំណត់របស់អ្នកប្រើប្រាស់កាតឡើយ ។ អ្នកផ្តល់កាតអាចទាមទារឱ្យទូទាត់ប្រាក់ដែលលើសចំនួនកម្រិតឥណទាន ឬសមតុល្យបំណុលភ្លាមៗតាមការកំណត់របស់អ្នកផ្តល់កាត ។ ការប្រើប្រាស់កាតលើសកម្រិតឥណទានដោយគ្មានការយល់ព្រមជាមុនពីអ្នកផ្តល់កាតនឹងត្រូវបានចាត់ទុកថាជាសកម្មភាពក្លែងបន្លំរបស់អ្នកប្រើប្រាស់កាត ។

## 19. ការបង្កើន/ បន្ថយកម្រិតឥណទាន

អ្នកប្រើប្រាស់កាតត្រូវផ្តល់សិទ្ធិដោយគ្មានលក្ខខណ្ឌដល់អ្នកផ្តល់កាតក្នុងការយល់ព្រមបង្កើន ឬបន្ថយកម្រិតឥណទានទោះជាមានការស្នើសុំពីអ្នកប្រើប្រាស់កាត ឬក៏យោងទៅលើប្រវត្តិរបស់គណនីនាពេលកន្លងមកក៏ដោយ ។ ការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកប្រើប្រាស់កាតមិនត្រូវបានអ្នកផ្តល់កាតកំណត់ឱ្យធ្វើឡើយក្នុងការបង្កើន ឬបន្ថយចំនួនណាមួយ ។ ហើយអ្នកផ្តល់កាតនឹងផ្ញើជូននូវលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីសំណើសុំការបង្កើន ឬបន្ថយកម្រិតឥណទានដល់អ្នកប្រើប្រាស់កាតភ្លាមៗតាមដែលអាចធ្វើបាន ។

## 20. វិធីសាស្ត្រទូទាត់

អ្នកប្រើប្រាស់កាតត្រូវទូទាត់រាល់ប្រតិបត្តិការ ថ្លៃសេវាកម្ម និងថ្លៃផ្សេងៗទៅឱ្យអ្នកផ្តល់កាតឱ្យបានមុន ឬនៅថ្ងៃកំណត់ ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍ ។ ការទូទាត់អាចត្រូវបានធ្វើឡើងនៅសាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តាមរយៈការទូទាត់ជាសាច់ប្រាក់សុទ្ធ មូលប្បទានប័ត្រ ឬការផ្ទេរប្រាក់ពីគណនីផ្សេងៗដែលមាននៅក្នុងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។

ការទូទាត់សងតាមរយៈការដកប្រាក់ដោយស្វ័យប្រវត្តិ នឹងត្រូវបានរៀបចំឡើងប្រសិនបើ

អ្នកប្រើប្រាស់កាតចម្បងបានដាក់ប្រាក់បញ្ញើក្នុងគណនីជាមួយអ្នកផ្តល់កាត។ អ្នកប្រើប្រាស់កាតត្រូវប្រាកដថាគណនីដែលបានកំណត់សម្រាប់ទូទាត់ត្រូវតែមានសមតុល្យគ្រប់គ្រាន់ដែលអាចទូទាត់រាល់ចំណាយលើកម្រិតឥណទាននានា។

ចំពោះការដាក់បញ្ញើឥណទានបម្រុងជាមូលប្បទានប័ត្រ អ្នកផ្តល់កាតទទួលយកតែមូលប្បទានប័ត្រ ណាដែលចេញដោយគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ចំពោះមូលប្បទានប័ត្រដ៏ទៃទៀតដែលចេញដោយគ្រឹះស្ថានហិរញ្ញវត្ថុនៅក្រៅប្រទេស អ្នកផ្តល់កាតនឹងមិនទទួលយកឡើយ។

ប្រសិនបើគណនីដែលបានកំណត់សម្រាប់ទូទាត់មិនមានសមតុល្យគ្រប់គ្រាន់ដើម្បីទូទាត់ប្រាក់បំណុលទេ នោះការទូទាត់កាតឥណទាននឹងមិនត្រូវបានធ្វើឡើយ ហើយអ្នកប្រើប្រាស់កាតត្រូវទូទាត់ដោយផ្ទាល់ ឬប្រយោលនូវចំនួនសមតុល្យបំណុលថ្លៃសេវាកម្ម និងការប្រាក់ឱ្យទាន់ពេលកំណត់។

## 21. ចំនួនត្រូវទូទាត់

អ្នកប្រើប្រាស់កាតត្រូវទទួលខុសត្រូវទូទាត់ចំនួនបំណុលទាំងអស់ឱ្យបានមុន ឬនៅថ្ងៃកំណត់ដូចដែលបានបញ្ជាក់នៅលើរបាយការណ៍ប្រចាំខែដែលបានផ្តល់ឱ្យអ្នកប្រើប្រាស់កាត។ អ្នកប្រើប្រាស់កាតមានជម្រើសក្នុងការទូទាត់ចំនួនបំណុលសរុបចំនួនបំណុលអប្បបរមា ឬចំនួនណាមួយក្នុងចន្លោះនៃចំនួនសរុប និងចំនួនអប្បបរមាឱ្យទៅអ្នកផ្តល់កាត។ ចំនួនអប្បបរមាត្រូវបានគណនាដោយបូកបញ្ចូលចំនួនដូចខាងក្រោម៖

- ចំនួនបំណុលសរុបគុណនឹងអត្រាភាគរយដែលបានកំណត់ដោយអ្នកផ្តល់កាត ឬក៏ចំនួនកំណត់អប្បបរមាមួយដែលកំណត់ដោយអ្នកផ្តល់កាត
- ចំនួនប្រាក់ដែលលើសពីកម្រិតឥណទាន
- ចំនួនបំណុលដែលនៅសល់ពីមុនទាំងអស់ប្រសិនបើមាន។ ប្រសិនបើកាលបរិច្ឆេទត្រូវទូទាត់ស្ថិតនៅថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យជាតិ ការទូទាត់ប្រាក់ត្រូវធ្វើឡើងក្នុងថ្ងៃធ្វើការក្រោយកាលបរិច្ឆេទបានកំណត់។

## 22. ការអនុវត្តលើការទូទាត់

ការទូទាត់ចំពោះគណនីត្រូវធ្វើឡើងដូចខាងក្រោម៖

- ថ្លៃសេវាកម្មដែលមិនទាន់ទូទាត់ និង/ ឬការប្រាក់ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ថ្លៃសេវាកម្ម និង/ ឬការប្រាក់ដែលត្រូវទូទាត់ប៉ុន្តែមិនបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ការផ្ទេរប្រាក់ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការសាច់ប្រាក់ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការទិញដែលបានបញ្ជាក់នៅក្នុរបាយការណ៍ណាមួយ
- ការផ្ទេរសមតុល្យដែលបានធ្វើរួច ប៉ុន្តែមិនទាន់មានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ

- ប្រតិបត្តិការសាច់ប្រាក់ដែលបានធ្វើរួច ប៉ុន្តែមិនទាន់បញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការទិញដែលបានធ្វើរួច ប៉ុន្តែមិនទាន់មានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ

ប្រសិនបើលោកអ្នកដាក់ប្រាក់បញ្ចើចូលក្នុងគណនីកាតរបស់លោកអ្នកជាមូលប្បទានប័ត្រ ឬប្រភេទប្រាក់បញ្ញើផ្សេងៗទៀតដែលមិនមែនជាសាច់ប្រាក់ នោះអ្នកផ្តល់កាតអាចពន្យារពេលការប្រើប្រាស់ឥណទានបម្រុងរហូតដល់មានការពិនិត្យផ្ទៀងផ្ទាត់ច្បាស់លាស់។ ប្រសិនបើមូលប្បទានប័ត្របញ្ញើឬប្រភេទប្រាក់បញ្ញើដែលមិនមែនជាសាច់ប្រាក់ នោះមិនមានសមតុល្យអាចទូទាត់បាន អ្នកផ្តល់កាតនឹងកត់ត្រានៅផ្នែកឥណពន្ធនៃគណនីម្ចាស់កាតក្នុងចំនួនដែលមិនអាចទូទាត់នោះ (ក្នុងករណីដែលប្រាក់បញ្ញើឥណទានបម្រុងនោះត្រូវបានកត់ត្រារួចនៅផ្នែកឥណទាននៃគណនីម្ចាស់កាត) រួមទាំងថ្លៃសេវាកម្មលើមូលប្បទានប័ត្រគ្មានសមតុល្យ។

## 23. ប្រតិបត្តិការរូបិយប័ណ្ណបរទេស

អ្នកប្រើប្រាស់កាតត្រូវទូទាត់រាល់ប្រតិបត្តិការនានាដោយរូបិយប័ណ្ណបរទេសជាប្រាក់ដុល្លារអាមេរិច។ អ្នកផ្តល់កាតនឹងត្រូវគិតថ្លៃសេវាកម្មប្តូរប្រាក់។ អត្រាប្តូរប្រាក់ដែលប្រើគឺជាអត្រាប្តូរប្រាក់ ទីផ្សារទូទៅដែលកំណត់ឱ្យដោយ Visa International តាមរយៈការកំណត់អត្រាទូទៅមួយថ្ងៃមុនពេលប្រតិបត្តិការត្រូវបានដំណើរការដោយ Visa International ។

## 24. អត្រាការប្រាក់

អត្រាភាគរយប្រចាំខែដែលត្រូវប្រើដើម្បីគណនាការប្រាក់នៅក្នុងគណនីកាតឥណទាន គឺបានបញ្ជាក់ នៅក្នុងប័ណ្ណផ្សព្វផ្សាយពីថ្លៃសេវាកម្ម និងកម្រៃផ្សេងៗដែលនឹងត្រូវបានកែប្រែពីពេលមួយទៅពេលមួយដោយអ្នកផ្តល់កាត។

## 25. រយៈពេលមិនគិតការប្រាក់ចំពោះប្រតិបត្តិការលក់

នៅក្នុងរបាយការណ៍នីមួយៗមានបញ្ជាក់អំពី "សមតុល្យចុងគ្រា" និង "ថ្ងៃកំណត់ទូទៅ" របស់របាយការណ៍នោះ។ ដើម្បីទទួលបានអត្ថប្រយោជន៍នៅក្នុងរយៈពេលមិនគិតការប្រាក់ នោះការទូទាត់គ្រប់ចំនួននៃ "សមតុល្យចុងគ្រា" ត្រូវតែធ្វើឡើងតាម "ថ្ងៃកំណត់" នៃរបាយការណ៍នីមួយៗ។

## 26. ការគណនាអត្រាការប្រាក់

អ្នកប្រើប្រាស់កាតយល់ព្រមទូទាត់ថ្លៃការប្រាក់ដែលត្រូវបានគិតចំពោះគណនី។ ការប្រាក់ត្រូវបានគណនាដូចខាងក្រោម៖

(ក) ប្រតិបត្តិការទិញ ថ្លៃសេវាកម្ម ការគិតថ្លៃផ្សេងៗ និងកំណត់ត្រាឥណពន្ធផ្សេងៗទៀតនៃគណនី (រួមទាំងប្រតិបត្តិការសាច់ប្រាក់)៖

ប្រសិនបើអ្នកប្រើប្រាស់កាតមិនមានលទ្ធភាពទូទាត់សមតុល្យបំណុលឱ្យបានមុន ឬត្រឹមថ្ងៃកំណត់ទេ អ្នកប្រើប្រាស់កាតត្រូវទូទាត់ការប្រាក់ឱ្យទៅអ្នកផ្តល់កាត។ ការប្រាក់ត្រូវបានគណនាដោយគិតពីថ្ងៃដែលបានធ្វើប្រតិបត្តិការរហូតដល់ថ្ងៃដែលអ្នកប្រើប្រាស់កាតទូទាត់សងគ្រប់ចំនួន។

(ខ) ប្រតិបត្តិការសាច់ប្រាក់៖ ការប្រាក់ត្រូវបានគណនាចាប់ពីថ្ងៃដែលប្រតិបត្តិការ

សាច់ប្រាក់ត្រូវបានកត់ត្រានៅផ្នែកឥណពន្ធនៃគណនីរហូតដល់ថ្ងៃអ្នកប្រើប្រាស់កាតទូទាត់គ្រប់ចំនួន។

ការទូទាត់ត្រូវបានកត់ត្រានៅផ្នែកឥណពន្ធនៃគណនីដូចបានពិពណ៌នានៅចំណុចទី20។ អ្នកផ្តល់កាតមានសិទ្ធិក្នុងការកែប្រែអត្រាការប្រាក់ពីពេលមួយទៅពេលមួយ តាមការសម្រេចចិត្តរបស់ខ្លួន។ អ្នកប្រើប្រាស់កាតនឹងត្រូវបានជូនដំណឹងជាមុន ចំនួន 30 ថ្ងៃអំពីការផ្លាស់ប្តូរអត្រាការប្រាក់។

## 27. ការមិនគោរពតាមកិច្ចសន្យា

អ្នកប្រើប្រាស់កាតនឹងត្រូវបានចាត់ទុកថាមិនគោរពតាមកិច្ចសន្យាៈ

(1) ប្រសិនបើអ្នកប្រើប្រាស់កាតមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ក្នុងករណីដែលសមតុល្យបំណុលដល់កំណត់ត្រូវទូទាត់ដោយអ្នកប្រើប្រាស់កាត។

(2) ប្រសិនបើអ្នកផ្តល់កាតយល់ឃើញថារាល់ការបញ្ជារបស់អ្នកប្រើប្រាស់កាត ឬការផ្តល់គណនី ឬសេវាជូនអ្នកប្រើប្រាស់កាតនឹងបណ្តាលឱ្យអ្នកផ្តល់កាតរំលោភច្បាប់ទោសទណ្ឌ ឬរាល់ការទាមទារដោយអាជ្ញាធរមានសមត្ថកិច្ច។

(3) នៅពេលដែលលោកអ្នកខកខានផ្តល់ជូនអ្នកផ្តល់កាតនូវព័ត៌មានដែលបានទាមទារយោងតាមលក្ខន្តិកៈនេះ ឬនៅពេលដែលមានការទាមទារដោយច្បាប់ក្នុងស្រុក ឬ បរទេស និយ័តករ ភ្នាក់ងាររដ្ឋាភិបាល ឬអាជ្ញាធរប្រមូលចំណូល (ទោះបីក្នុងស្រុក ឬក្រៅស្រុក)។

ប្រសិនបើអ្នកប្រើប្រាស់កាតមានគណនីមួយ ឬច្រើនជាងនេះជាមួយអ្នកផ្តល់កាត រាល់ការមិនគោរពកិច្ចសន្យានៅក្នុងគណនីណាមួយ នឹងត្រូវបានចាត់ទុកដូចគ្នាចំពោះគណនីផ្សេងទៀតផងដែរ។ ទោះក្នុងករណីណាក៏ដោយ នៅពេលអ្នកប្រើប្រាស់កាតមិនគោរពតាមកិច្ចសន្យា អ្នកផ្តល់កាតរក្សាសិទ្ធបញ្ឈប់គណនីទាំងអស់របស់អ្នកប្រើប្រាស់កាតដែលមានជាមួយអ្នកផ្តល់កាត។

ប្រសិនបើអ្នកប្រើប្រាស់កាតមិនអាចទូទាត់សមតុល្យបំណុលក្នុងរយៈពេល 60 ថ្ងៃនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់កាត នោះត្រូវបានចាត់ទុកថា អ្នកប្រើប្រាស់កាតមិនគោរពតាមកិច្ចសន្យា។

(ក) អ្នកប្រើប្រាស់កាតបានផ្តល់ការធានាតាមរយៈគណនីប្រាក់បញ្ញើដោយផ្តល់សិទ្ធិ និងអនុញ្ញាតឱ្យអ្នកផ្តល់កាតដើម្បីដកប្រាក់ពីគណនីសន្សំ/ ប្រាក់បញ្ញើរបស់អ្នកប្រើប្រាស់កាតដោយមិនចាំបាច់មានការយល់ព្រម ឬបញ្ជាក់ពីអ្នកប្រើប្រាស់កាតក្នុងការទូទាត់សមតុល្យបំណុលខ្លះ ឬទាំងអស់ឡើយ ឬ

(ខ) អ្នកប្រើប្រាស់កាត បានផ្តល់ “ការធានារបស់ក្រុមហ៊ុន” សម្រាប់ធានាឥណទាន

អ្នកប្រើប្រាស់កាតផ្តល់សិទ្ធិឱ្យអ្នកផ្តល់កាតទារប្រាក់ទូទាត់សមតុល្យបំណុលពីក្រុមហ៊ុនដែលបានផ្តល់ការធានាចំពោះគណនីអ្នកប្រើប្រាស់កាតដោយមិនចាំបាច់មានការយល់ព្រម និងការបញ្ជាក់បន្ថែមពីអ្នកប្រើប្រាស់កាតថែមទៀតឡើយ។

ចំពោះការមិនគោរពតាមកិច្ចសន្យា អ្នកប្រើប្រាស់កាតយល់ព្រមអនុញ្ញាតឱ្យអ្នកផ្តល់កាតអាចអនុវត្តសកម្មភាពមួយ ឬច្រើនជាងនេះដូចខាងក្រោមតាមការសម្រេចចិត្តរបស់អ្នក

ផ្តល់កាត៖

- បញ្ឈប់សិទ្ធិប្រើប្រាស់កាត និងចាត់ចែងតាមនីតិវិធីដើម្បីទារការទូទាត់សមតុល្យទាំងអស់ត្រូវធ្វើការទូទាត់ចំពោះការទូទាត់សងយឺត និង/ថ្លៃសេវាកម្មលើសកំណត់ដូចបានបញ្ជាក់ ដោយអ្នកផ្តល់កាត
- អនុវត្តសកម្មភាពទារបំណុលដែលជិពាក់រួមទាំងសកម្មភាពផ្លូវច្បាប់ផងដែរ
- មានសិទ្ធិចុះហត្ថលេខាលើឯកសារណាមួយជំនួសមុខអ្នកប្រើប្រាស់កាត និងអនុវត្តសកម្មភាពចាំបាច់ណាមួយដើម្បីទារបំណុល
- ចុះឈ្មោះអ្នកប្រើប្រាស់កាតទៅក្នុងបញ្ជីឈ្មោះ អ្នកមិនគោរពកិច្ចសន្យា ឬបញ្ជីឈ្មោះប្រហាក់ប្រហែលនេះដែលអ្នកផ្តល់កាត ស្ថាប័នរដ្ឋាភិបាល ឬស្ថាប័នផ្សេងៗធ្វើឡើង និង
- អនុវត្តតាមនិតិវិធីច្បាប់ អ្នកផ្តល់កាតមានសិទ្ធិអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតក្នុងការទារបំណុលដោយរឹបអូសយកប្រាក់ ឬទ្រព្យសម្បត្តិណាមួយក្នុងនាមអ្នកប្រើប្រាស់កាត។

## ថ្លៃសេវាកម្ម

### 28. ថ្លៃសេវាកម្ម

បន្ថែមពីលើការប្រាក់ អ្នកប្រើប្រាស់កាតត្រូវទូទាត់ថ្លៃសេវាកម្ម និងថ្លៃផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកាត ប៉ុន្តែមិនកំណត់ត្រឹមថ្លៃសេវាកម្មខាងក្រោម៖

(1) ថ្លៃសេវាកម្មប្រចាំឆ្នាំ ថ្លៃសេវាកម្មបន្ថែមរបស់កាត (ត្រូវបានគិតម្តងក្នុងមួយឆ្នាំ)

(2) ថ្លៃសេវាកម្មដកសាច់ប្រាក់សុទ្ធ (ប្រាក់ដែលបានដក)៖ ត្រូវបានគិតនៅពេលអ្នកប្រើប្រាស់កាតដកប្រាក់ពីម៉ាស៊ីន ATM ឬធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត

(3) ថ្លៃសេវាកម្មប្តូររូបិយប័ណ្ណបរទេស៖ ត្រូវបានគិតចំពោះប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេសជាប្រាក់ដុល្លារអាមេរិចនិងអាស្រ័យទៅលើប្រតិបត្តិការរូបិយប័ណ្ណបរទេស និងពេលប្រតិបត្តិការដែលត្រូវបានកត់ត្រាផ្នែកឥណពន្ធនៃគណនី

(4) ថ្លៃសេវាកម្មចាយលើសកម្រិតឥណទាន៖ ត្រូវបានគិតចំពោះសមតុល្យបំណុលលើសចំនួនកំណត់

(5) ថ្លៃសេវាកម្មលើការទូទាត់យឺត៖ ត្រូវបានគិតប្រសិនបើអ្នកប្រើប្រាស់មិនមានលទ្ធភាពយ៉ាងហោចណាស់បង់ចំនួនអប្បបរមាឱ្យបានមុន ឬនៅថ្ងៃកំណត់

(6) ថ្លៃសេវាកម្មចម្លងរបាយការណ៍៖ ត្រូវបានគិតនៅពេលអ្នកប្រើប្រាស់កាតស្នើសុំច្បាប់ចម្លងនៃរបាយការណ៍ច្បាប់ដើម

(7) ថ្លៃសេវាកម្មលើការស្នើសុំមិនត្រឹមត្រូវឱ្យបង្វិលប្រាក់សងវិញ៖ ត្រូវបានគិតទៅតាមការសម្រេចចិត្តរបស់អ្នកផ្តល់កាតនៅពេលការស្នើសុំបង្វិលប្រាក់សងវិញរបស់អ្នកប្រើប្រាស់កាតត្រូវបានចាត់ទុកថាមានភាពមិនត្រឹមត្រូវ ឬខុស

(8) ថ្លៃសេវាកម្មលើការប្តូរកាត៖ ត្រូវបានគិតនៅពេលអ្នកប្រើប្រាស់កាតស្នើសុំប្តូរកាតមុនកាលបរិច្ឆេទផុតកំណត់

(9) ថ្លៃសេវាកម្មលើមូលប្បទានប័ត្រគ្មានសមតុល្យ៖ នៅពេលការបង់ប្រាក់ទូទាត់សងរបស់លោកអ្នកមិនមានសមតុល្យគ្រប់គ្រាន់អាចធ្វើការទូទាត់បាន នោះថ្លៃសេវាកម្មមូលប្បទានប័ត្រគ្មានសមតុល្យនឹងត្រូវបានគិតពីគណនីរបស់លោកអ្នក។

(10) ថ្លៃសេវាកម្មស្នើសុំពិសេស៖ ត្រូវបានគិតនៅពេលអ្នកប្រើប្រាស់កាតស្នើសុំបន្ថែម ឬស្នើសុំពិសេសណាមួយដែលអ្នកផ្តល់កាតត្រូវធ្វើ។ ថ្លៃសេវាកម្មនេះអាចមានតម្លៃខុសគ្នាទៅតាមការស្នើសុំ និងអាចត្រូវបានគិតបញ្ចូលថ្លៃសេវាកម្មសម្រាប់ការផ្ញើកាតជំនួសថ្មីទៅបរទេស។

ថ្លៃសេវាកម្មអាចត្រូវបានគិតដោយផ្អែកលើអត្រានៃតម្លៃរបស់ប្រតិបត្តិការ/ សមតុល្យដែលបានកំណត់ជាមុន ឬអត្រាថេរអប្បបរមា ឬក៏អត្រាទាំងពីររួមគ្នា។

ថ្លៃសេវាកម្មទាំងអស់នឹងត្រូវបានកត់ត្រាផ្នែកឥណពន្ធនៃគណនីរួមទាំងរបាយការណ៍នៅក្នុងគ្រា ឬគ្រាបន្ទាប់។

ព័ត៌មានលម្អិតនៃអត្រាខាងលើក៏មាននៅក្នុងតារាងថ្លៃសេវាកម្មរបស់អ្នកផ្តល់កាតផងដែរ។ អ្នកផ្តល់កាតរក្សាសិទ្ធិកែប្រែរចនាសម្ព័ន្ធថ្លៃសេវាកម្ម ឬថ្លៃសេវាកម្មណាមួយ។ អ្នកផ្តល់កាតនឹងជូនដំណឹងដល់អ្នកប្រើប្រាស់កាតជាមុនចំនួន 30 ថ្ងៃចំពោះការផ្លាស់ប្តូរថ្លៃសេវាកម្ម និងថ្លៃផ្សេងៗដូចពន្យល់លម្អិតនៅក្នុងតារាងថ្លៃសេវាកម្មរបស់អ្នកផ្តល់កាត។

## បទបញ្ញត្តិផ្សេងទៀត

## 29. ការព្រមព្រៀងចំពោះព័ត៌មានផ្ទាល់ខ្លួន

លោកអ្នកព្រមឱ្យអ្នកផ្តល់កាតបើកចំហរព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកដល់៖

(ក) អង្គការ រឺក្រុមហ៊ុនណាមួយដែលកំពុងមានការរៀបចំ ឬជាសម្ព័ន្ធភាពសហការជាមួយអ្នកផ្តល់កាត

(ខ) អ្នកផ្តល់ថ្លៃសេវាកម្មណាមួយដែលអ្នកផ្តល់កាតបានជួលឱ្យអនុវត្ត ឬឱ្យជួយបំពេញមុខងារ និងសកម្មភាពរបស់ខ្លួន

(គ) អ្នកផ្តល់កិច្ចធានា អ្នកផ្តល់សិទ្ធិ ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិ រឺនរណាម្នាក់ដែលកំពុងទទួលបានការគិតគូរឱ្យក្លាយទៅជាជនណាមួយខាងលើ និង

(ឃ) ការិយាល័យឥណទាន ឬការិយាល័យបញ្ជីការប្រហាក់ប្រហែលក្នុងគោលបំណងអនុវត្តការត្រួតពិនិត្យឥណទាន និង

(ង) ទៅបុគ្គលណាម្នាក់ទៀតរួមមានភ្នាក់ងាររដ្ឋាភិបាល ឬអាជ្ញាធរប្រមូលចំណូល ទោះបីក្នុងស្រុក ឬបរទេសដែលទាមទារដោយច្បាប់ក្នុងស្រុក ឬបរទេស និង/ ឬកិច្ចព្រមព្រៀងជាមួយអ្នកផ្តល់កាត។។

## 30. កាតបន្ទាប់បន្សំ

អ្នកប្រើប្រាស់កាតចម្បងអាចផ្តល់សិទ្ធិដល់អ្នកផ្តល់កាត ក្នុងការចេញកាតបន្ទាប់បន្សំ និង

យល់ព្រមឱ្យអ្នកផ្តល់កាតគិតថ្លៃឈ្នួលចេញពីកាតបន្ទាប់បន្សំ ។ អ្នកប្រើប្រាស់កាតបន្ទាប់បន្សំត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ។

ចំនួនកាតបន្ទាប់បន្សំអាចខុសគ្នាអាស្រ័យលើគោលការណ៍ដែលមានស្រាប់របស់អ្នកផ្តល់កាត ។ ការសម្រេចចិត្តចេញកាតបន្ទាប់បន្សំគឺជាការសម្រេចចិត្តរបស់អ្នកផ្តល់កាតតែម្នាក់ប៉ុណ្ណោះ ។ ការប្រើប្រាស់កាតបន្ទាប់បន្សំត្រូវមានការអនុញ្ញាតយល់ព្រម និងជូនដំណឹងពីអ្នកប្រើប្រាស់កាតចម្បង ។

អ្នកប្រើប្រាស់កាតចម្បងអាចស្នើសុំកែប្រែសិទ្ធិប្រើប្រាស់កាតបន្ទាប់បន្សំដែលជាប់ទាក់ទងនឹងគណនីរបស់ខ្លួនដោយទាក់ទងផ្ទាល់មកអ្នកផ្តល់កាត ឬតាមទូរស័ព្ទ ឬក៏ជាលិខិតលាយលក្ខណ៍អក្សរ ។ អ្នកផ្តល់កាតនឹងបដិសេធសិទ្ធិប្រើប្រាស់កាតបន្ទាប់បន្សំនៅពេលអ្នកប្រើប្រាស់កាតចម្បងបានបញ្ជូនកាតឥណទានត្រលប់មកអ្នកផ្តល់កាតវិញ ឬបានបំពេញលក្ខខណ្ឌសមហេតុផលដើម្បីបញ្ជូនកាតត្រលប់មកអ្នកផ្តល់កាតវិញ ។

## 31. ការកែប្រែបទបញ្ញត្តិ និងលក្ខខណ្ឌ

យោងទៅតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានផ្តល់ជូនជាមុនចំនួន 30 ថ្ងៃ ឬតាមវិធីណាមួយផ្សេងទៀតដែលត្រូវបានផ្ញើទៅកាន់អ្នកប្រើប្រាស់កាត នោះអ្នកផ្តល់កាតអាចកែប្រែ ឬកែសម្រួលរាល់លក្ខខណ្ឌនានាបានគ្រប់ពេលទោះក្នុងមូលហេតុអ្វីក៏ដោយរួមទាំងចំនួនប្រាក់កំណត់របស់អ្នកប្រើប្រាស់កាត ហើយអ្នកប្រើប្រាស់កាតត្រូវអនុវត្តតាមការកែប្រែនេះ លើកលែងតែអ្នកប្រើប្រាស់កាតបដិសេធដោយបង្ហាញពីគោលបំណងក្នុងការបញ្ចប់កិច្ចសន្យាតាមលក្ខខណ្ឌបានចែងក្នុងចំណុចទី 15 ។

## 32. ការទទួលខុសត្រូវរបស់អ្នកផ្តល់កាតការខូចខាត

អ្នកផ្តល់កាតនឹងមិនទទួលខុសត្រូវចំពោះបំណុលណាមួយដែលកើតឡើង ឬមានការពាក់ព័ន្ធជាមួយអ្នកប្រើប្រាស់កាតចំពោះកិច្ចសន្យានេះឡើយ ។

## 33. ការលើកលែងចំពោះការបំពានកិច្ចសន្យា

គ្មានការលើកលែងណាមួយពីអ្នកផ្តល់កាតចំពោះការរំលោភបំពាន ឬមិនគោរពលក្ខខណ្ឌទាំងនេះនឹងត្រូវប្រើដើម្បីលើកលែងចំពោះការរំលោភបំពាន ឬការមិនគោរពលក្ខខណ្ឌដូចគ្នា ឬលក្ខខណ្ឌផ្សេងណាមួយនាពេលបន្ទាប់ឡើយ ។ ការខកខានដោយអ្នកផ្តល់កាតក្នុងការទទួលយកប្រយោជន៍ឬប្រើសិទ្ធណាមួយដែលបានផ្តល់ឱ្យដូចមាននៅក្នុងលក្ខខណ្ឌនឹងមិនត្រូវចាត់ជាការលើកលែងដែលបញ្ជាក់អំពីសិទ្ធិហើយថែមទាំងមិនអាចចាត់ទុកជាការបកស្រាយដើម្បីដោះសារ ឬលើកលែងទោសអ្នកប្រើប្រាស់កាតចំពោះការប្រព្រឹត្តិ ឬបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ។

## 34. ភាពដែលអាចចាត់ទុកដោយឡែក

ចំពោះលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំងអស់នេះ ឬផ្នែកណាមួយ ឬប្រយោគណាមួយដែលត្រូវបានប្រកាសជាមោឃៈ ឬមិនអាចបង្ខំឱ្យអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចបាននោះនឹងមិនមានការប៉ះពាល់ដល់សុពលភាពលក្ខខណ្ឌផ្នែកប្រយោគផ្សេងទៀតឡើយ ។ កិច្ចសន្យានេះនឹងត្រូវបានចាត់ទុកថាមិនមានការបញ្ជាក់អំពីការព្រមព្រៀងកាតព្វកិច្ច និងសិទ្ធិទាំងនោះរបស់អ្នកប្រើប្រាស់កាត និងអ្នកផ្តល់កាតឡើយ ហើយកិច្ចសន្យានេះនឹងនៅមានតម្លៃតាមផ្លូវច្បាប់ដដែល ។

## 35. ច្បាប់គ្រប់គ្រង

កិច្ចសន្យានេះស្ថិតនៅក្រោមច្បាប់ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យានេះគឺជាបទបញ្ញត្តិស្តីពីការផ្តល់ការប្រើប្រាស់ និងការទូទាត់កាតឥណទាន។

## 36. ជម្លោះ

ក្នុងករណីមានជម្លោះណាមួយដែលមិនត្រូវបានដោះស្រាយការចរចាសម្របសម្រួលបាន នោះជាកាតព្វកិច្ចរបស់ភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយដោយយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## 37. កាតដែលមានការធានា

អ្នកផ្តល់កាតអាចសម្រេះសម្រួលជាមួយអ្នកប្រើប្រាស់កាតដើម្បីទទួលបានវិធីសាស្ត្រមួយ ឬច្រើនក្នុងការធានាលើការទូទាត់បំណុលរបស់អ្នកប្រើប្រាស់កាតតាមកិច្ចសន្យា។ ប្រសិនបើកាតមានការធានាដែលត្រូវបានផ្តល់ឱ្យដោយអ្នកផ្តល់កាតនោះទម្រង់នៃការធានាដែលផ្តល់ឱ្យដោយអ្នកផ្តល់កាតនឹងត្រូវបានយល់ព្រមជាលាយលក្ខណ៍អក្សរ ហើយឯកសារណាមួយដែលមានការពាក់ព័ន្ធនឹងត្រូវចាត់ទុកជាផ្នែកសំខាន់នៃកិច្ចសន្យា។

## 38. ការប្រឆាំងការលាងលុយកខ្វក់ ភេរវកម្មហិរញ្ញវត្ថុ និងការត្រួតពិនិត្យទណ្ឌកម្មហិរញ្ញវត្ថុ

លោកអ្នកយល់ព្រមថា អ្នកផ្តល់កាត អាចនឹងពន្យារពេល ឬបដិសេធមិនធ្វើប្រតិបត្តិការណាមួយដោយមិនទទួលខុសត្រូវអ្វីទាំងអស់ ប្រសិនបើអ្នកផ្តល់កាតមានមន្ទិលសង្ស័យថា៖

(ក) ប្រតិបត្តិការអាចរំលោភលើច្បាប់ ឬបទបញ្ញត្តិណាមួយនៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត

(ខ) ប្រតិបត្តិការដែលជាប់ពាក់ព័ន្ធនឹងអង្គភាពណាមួយ (បុគ្គល សហជីព ឬរដ្ឋាភិបាល) ដែលមានទណ្ឌកម្ម ឬជាប់ពាក់ព័ន្ធគ្នាដោយផ្ទាល់ ឬដោយប្រយោលចំពោះបុគ្គលដែលមានទណ្ឌកម្មស្ថិតក្រោមទណ្ឌកម្ម សេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលកំណត់ដោយសហរដ្ឋអាមេរិច សហគមន៍អឺរ៉ុប ឬប្រទេសដ៏ទៃ ឬ

(គ) ប្រតិបត្តិការអាចទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងមូលនិធិដែលទទួលបានដោយខុសច្បាប់ក្នុងប្រទេសកម្ពុជា ឬប្រទេសថៃ។

លោកអ្នកត្រូវផ្តល់ព័ត៌មានទាំងអស់មកអ្នកផ្តល់កាត ដែលអ្នកផ្តល់កាតតម្រូវឱ្យមានការគ្រប់គ្រងការលាងលុយកខ្វក់ ភេរវកម្មហិរញ្ញវត្ថុ ឬទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្ម ឬដើម្បីអនុលោមទៅតាមច្បាប់ ឬបទបញ្ញត្តិនានានៅក្នុងប្រទេសកម្ពុជា ឬប្រទេសដ៏ទៃ។ យោងទៅតាមការចាត់ចែង ការស្នើសុំ ឬតម្រូវការ (មាន ឬមិនមានក្នុងច្បាប់) ដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចដ៏ទៃទៀត។ លោកអ្នកយល់ព្រមថា អ្នកផ្តល់កាតអាចបង្ហាញព័ត៌មានអតិថិជនដល់៖

(ក) ភ្នាក់ងារអនុវត្តច្បាប់ តុលាការ ឬនិយ័តករ ដែលតម្រូវដោយច្បាប់ ឬបទបញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ឬប្រទេសដ៏ទៃ

(ខ) ឯកសារដែលទាក់ទងជាមួយអ្នកផ្តល់កាតប្រើប្រាស់ដើម្បីធ្វើការទូទាត់សម្រាប់គោលបំណងនៃច្បាប់ ឬបទបញ្ញត្តិណាមួយ។

(គ) នៅពេលដែលអ្នកផ្តល់កាត ឬសម្ព័ន្ធក្រុមហ៊ុនដែលតម្រូវអោយស្របតាមការចាត់តាំង ការស្នើសុំ ឬតម្រូវការ (មាន ឬមិនមាននៅក្នុងច្បាប់) ដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសណាមួយ និង

(ឃ) អ្នកផ្តល់កាត ឬសម្ព័ន្ធក្រុមហ៊ុន ឬអ្នកផ្តល់សេវាកម្មរបស់អ្នកផ្តល់កាត ឬសម្ព័ន្ធក្រុមហ៊ុនដើម្បីការងាររដ្ឋបាល និងប្រតិបត្តិ (ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងហានិភ័យ បំណុលដែលទូទាត់បានមកវិញ ការផ្សព្វផ្សាយដំណើរការទិន្នន័យ ប្រព័ន្ធនៃការអភិវឌ្ឍន៍ និងសាកល្បងការកត់ត្រាលើឥណទានការបណ្តុះបណ្តាលបុគ្គលិក ផ្នែកទីផ្សារ និងការស្វែងយល់ពីតម្រូវការរបស់អតិថិជន) ។

លុះត្រាតែលោកអ្នកបានបញ្ជាក់ប្រាប់ជាមុនថា លោកអ្នកធ្វើឡើងក្នុងនាមជាអ្នកដែលត្រូវបាន ផ្តល់ការទុកចិត្ត ឬជាភាគីមួយផ្សេងទៀត បើមិនដូច្នោះទេ មានន័យថាលោកអ្នក និងអ្នកតំណាងដែលទទួលបានសិទ្ធិពីលោកអ្នកបានធ្វើអ្វីៗក្នុងនាមលោកអ្នកក្នុងការចុះកិច្ចព្រមព្រៀងនេះ ។

លោកអ្នកយល់ព្រមទទួលខុសត្រូវចំពោះអ្នកផ្តល់កាតថា រាល់ដំណើរការប្រតិបត្តិទាំងអស់របស់លោកអ្នកជាមួយអ្នកផ្តល់កាត នឹងមិនរំលោភលើច្បាប់ ឬបទបញ្ញត្តិណាមួយរបស់ប្រទេសកម្ពុជា ឬច្បាប់ប្រទេសណាមួយផ្សេងទៀតឡើយ ។

## 39. ការផ្ទេរសិទ្ធិរបស់អ្នកផ្តល់កាត

ដោយមិនចាំបាច់ជម្រាបជូន ឬយល់ព្រមពីលោកអ្នកជាមុន អ្នកផ្តល់កាតមានសិទ្ធិ៖

(ក) អនុវត្តសិទ្ធណាមួយរបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចសន្យានេះ និង

(ខ) ផ្តល់ព័ត៌មានអំពីកិច្ចសន្យា និងកាតព្វកិច្ចរបស់លោកអ្នកនៅក្នុងកិច្ចសន្យានេះឱ្យទៅអ្នកដែលទទួលបានសិទ្ធិពីអ្នកផ្តល់កាតដោយយោងតាមសិទ្ធិរបស់អ្នកផ្តល់កាតដែលមានចែងនៅក្នុងកិច្ចសន្យានេះ ឬអ្នកផ្សេងទៀតដែលនឹងអាចទទួលបានសិទ្ធិពីអ្នកផ្តល់កាត ។

បើមានការស្នើសុំពីអ្នកផ្តល់កាត អ្នកប្រើប្រាស់កាតត្រូវប្រតិបត្តិ ឬបំពេញឯកសារណាមួយនៅពេលអ្នកផ្តល់កាតរៀបចំការផ្ទេរសិទ្ធិណាមួយដែលបានបញ្ជាក់នៅក្នុងប្រយោគនេះ ។

## 40. ការប្រមូលព័ត៌មាន

អ្នកប្រើប្រាស់កាតយល់ព្រមផ្តល់ឱ្យអ្នកផ្តល់កាត នូវព័ត៌មាន និងឯកសារទាំងអស់តាមការតម្រូវម្តងម្កាលរបស់អ្នកផ្តល់កាត រួមទាំងតម្រូវការផ្សេងៗផងដែរ យោងតាមច្បាប់/ បទបញ្ញត្តិបរទេស និង/ ឬតាមរយៈកិច្ចព្រមព្រៀងជាមួយនឹងភ្នាក់ងាររដ្ឋាភិបាល ឬអាជ្ញាធរប្រមូលចំណូល (ទោះបីក្នុងស្រុក ឬបរទេស) ដើម្បីធ្វើការសាកសួរអំពីស្ថានភាពពន្ធរបស់អ្នកប្រើប្រាស់កាត ។ អ្នកប្រើប្រាស់កាតទទួលស្គាល់ថា ព័ត៌មានទាំងអស់ដែលផ្តល់ឱ្យអ្នកផ្តល់កាតមានភាពត្រឹមត្រូវ ពេញលេញ មានបច្ចុប្បន្នភាព និងមិនបង្កឱ្យមានការយល់ច្រលំឡើយ ។

## 41. ពន្ធ

អ្នកផ្តល់កាត អាចមានការចាំបាច់ក្នុងការកាត់ទុកនូវទឹកប្រាក់ដែលបានបង់ចំពោះម្ចាស់គណនីមួយចំនួន រួចផ្ទេរទឹកប្រាក់នោះទៅឱ្យភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក ឬបរទេស ឬអាជ្ញាធរប្រមូលចំណូលយោងតាមច្បាប់ក្នុងស្រុក ឬបរទេស ឬតាមរយៈកិច្ចព្រមព្រៀង

ជាមួយនឹងអាជ្ញាធរទាំងនោះ ។

ប្រសិនបើនៅពេលណាមួយភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក ឬបរទេស ឬអាជ្ញាធរប្រមូលចំណូលតម្រូវឱ្យអ្នកផ្តល់កាតធ្វើការកាត់ទុក ឬដកចំនួនទឹកប្រាក់ណាមួយដែលត្រូវបង់ដោយលោកអ្នក លោកអ្នកយល់ព្រមភ្លាមក្នុងការសងអ្នកផ្តល់កាត សម្រាប់ចំនួនទឹកប្រាក់នៃការកាត់ទុក ឬដកទុកនោះ រួមទាំងអនុញ្ញាតឱ្យអ្នកផ្តល់កាត កាត់ទឹកប្រាក់ទាំងនោះពីគណនីលោកអ្នកផងដែរ ។ លោកអ្នកត្រូវចេញសងអ្នកផ្តល់កាត ចំពោះការខាតបង់ ឬការចំណាយរបស់អ្នកផ្តល់កាត ដែលបានកើតឡើងដោយសារការកាត់ទុក ឬការដកទុកនោះ ។

## សាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

រាជធានីភ្នំពេញ
សាខាក្រមួនស (ការិយាល័យកណ្តាល)
ផ្ទះលេខ 20 វិថីក្រមួនស
កែងផ្លូវលេខ 67

សាខាវិមានឯករាជ្យ
ផ្ទះលេខ 100 មហាវិថីសម្តេចព្រះសីហនុ

សាខាផ្សារអូឡាំពិក
ផ្ទះលេខ 259-361 និង 363
មហាវិថីសម្តេចព្រះសីហនុ

សាខាមាត់ទន្លេ
ផ្ទះលេខ 265 តីរវិថីព្រះស៊ីសុវត្ថិ

សាខាផ្សារដើមថ្កូវ
ផ្ទះលេខ 616A-B ផ្លូវលេខ 271

សាខាពេទ្យលោកសង្ឃ
ផ្ទះលេខ 1A-1B ផ្លូវលេខ 271

សាខាទឹកថ្លា
ផ្ទះលេខ 1E0-1E1 ផ្លូវលេខ 110A

សាខាស្ទឹងមានជ័យ
ផ្ទះលេខ 23-25A ផ្លូវលេខ 217

សាខាចោមចៅ
ផ្ទះលេខ 1B-2B និង 3B ផ្លូវជាតិលេខ 4

សាខាទួលគោក
ផ្ទះលេខ 95C មហាវិថីលេខ 289

សាខាខេត្ត
សាខាខេត្តសៀមរាប ផ្សារកណ្តាល
ផ្ទះលេខ 566-568 និង 570 ផ្លូវទេពវង្ស

សាខាខេត្តព្រះសីហនុ
ផ្ទះលេខ 219 វិថីឯករាជ្យ

សាខាខេត្តបាត់ដំបង
ផ្ទះលេខ 2-4 និង 6 ផ្លូវ 1 ភូមិ20 ឧសភា

សាខាខេត្តកំពង់ចាម
វិថីព្រះមុនីវង្ស
កែងវិថីនារីរ័ត្នកុសមៈ ភូមិ 12

ឬតាមរយៈទូរស័ព្ទលេខ:
ក្នុងស្រុក 023 999 000
អន្តរជាតិ +855 23 999 000
Email: ccc@jtrustroyal.com
SWIFT: TCABKHPP

J Trust Royal Bank

Tel: +855 23 999 000
Email: ccc@jtrustroyal.com
SWIFT: TCABKHPP
URL: www.jtrustroyal.com